ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខៈ ៧ អយក.សាលាន

# សេចក្ដីណែនាំ
## ស្ដីពី
## ការអនុវត្តប្រកាសលេខ ១៥៤ អយក.ប្រក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ សម្រាប់ឆ្នាំសិក្សា ២០២៥-២០២៦

ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ សម្រាប់ឆ្នាំសិក្សា២០២៥-២០២៦ ក្រសួងអប់រំ យុវជន និងកីឡា បន្តប្រគល់សិទ្ធិអំណាច និងការទទួលខុសត្រូវទាំងស្រុង ជូនគ្រឹះស្ថានមធ្យមសិក្សានីមួយៗ រៀបចំការប្រឡងចាប់តាំងពីការរៀបចំវិញ្ញាសា ដំណើរការសំណេរ កំណែ ស្រង់បូកពិន្ទុ និងប្រកាសលទ្ធផលនៅតាមគ្រឹះស្ថានមធ្យមសិក្សានីមួយៗ។ គ្រឹះស្ថានមធ្យមសិក្សានីមួយៗ ត្រូវប្រើប្រាស់បុគ្គលិកអប់រំ នៅក្នុងគ្រឹះស្ថានមធ្យមសិក្សារបស់ខ្លួនធ្វើជាមេប្រយោគប្រឡង។ មន្ទីរអប់រំ យុវជន និងកីឡា មានភារកិច្ចបញ្ជូនមន្ត្រីជំនាញ ដើម្បីត្រួតពិនិត្យតាមមណ្ឌលប្រឡងមួយចំនួន ក្នុងករណីចាំបាច់ដោយប្រើប្រាស់ថវិកាកម្មវិធីរបស់អង្គភាព និងមានភារកិច្ចចេញវិញ្ញាបនបត្របណ្ដោះអាសន្នមធ្យមសិក្សាបឋមភូមិ ជូនដល់បេក្ខជនទាំងអស់ដែលប្រឡងជាប់។ ដូច្នេះ ដើម្បីឱ្យគ្រឹះស្ថានមធ្យមសិក្សានីមួយៗ មានមូលដ្ឋានក្នុងការរៀបចំប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ឱ្យប្រព្រឹត្តទៅបានល្អប្រសើរ ក្រសួងសូមធ្វើការណែនាំ ដូចតទៅ៖

### ១. សម័យប្រឡង និងកាលបរិច្ឆេទ នៃការទទួលពាក្យសុំប្រឡង

- សម័យប្រឡង៖ **៦ កក្កដា ២០២៦**
- ប្រកាសលទ្ធផល៖ **ថ្ងៃចន្ទ ទី១៣ ខែកក្កដា ឆ្នាំ២០២៦**
- ការទទួល និងដាក់ពាក្យសុំប្រឡង៖ **ថ្ងៃទី១ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៦។**

### ២. វិញ្ញាសា ថេរវេលា និងរបបពិន្ទុ

| | | |
|---|---|---|
| – តែងសេចក្ដី | រយៈពេល ៩០ នាទី | ពិន្ទុពី ០ ដល់ ៦០ |
| – ការសរសេរតាមអាន | រយៈពេល ៦០ នាទី | ពិន្ទុពី ០ ដល់ ៤០ |
| – គណិតវិទ្យា | រយៈពេល ១២០ នាទី | ពិន្ទុពី ០ ដល់ ១០០ |
| – រូបវិទ្យា | រយៈពេល ៤៥ នាទី | ពិន្ទុពី ០ ដល់ ៣៥ |
| – គីមីវិទ្យា | រយៈពេល ៣០ នាទី | ពិន្ទុពី ០ ដល់ ២៥ |
| – ជីវវិទ្យា | រយៈពេល ៤៥ នាទី | ពិន្ទុពី ០ ដល់ ៣៥ |
| – ផែនដី និងបរិស្ថានវិទ្យា | រយៈពេល ៣០ នាទី | ពិន្ទុពី ០ ដល់ ២៥ |
| – សីលធម៌-ពលរដ្ឋវិជ្ជា | រយៈពេល ៤៥ នាទី | ពិន្ទុពី ០ ដល់ ៣៥ |
| – ភូមិវិទ្យា | រយៈពេល ៤០ នាទី | ពិន្ទុពី ០ ដល់ ៣២ |
| – ប្រវត្តិវិទ្យា | រយៈពេល ៤០ នាទី | ពិន្ទុពី ០ ដល់ ៣៣ |
| – ភាសាបរទេស | រយៈពេល ៤៥ នាទី | ពិន្ទុពី ០ ដល់ ៥០ |


អាសយដ្ឋាន៖ អគារលេខ ៨០ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
info@moeys.gov.kh / administration@moeys.gov.kh
ទូរស័ព្ទ៖ (+៨៥៥) ២៣ ២២០ ៦៧៣ / ២២០ ៣០៤
www.moeys.gov.kh

**សម្គាល់៖** - ថេរវេលានៃវិញ្ញាសានីមួយៗ គិតពីពេលកត់វិញ្ញាសាលើក្ដារខៀនចប់
- ចំពោះបេក្ខជនគថ្លង់មិនប្រឡងវិញ្ញាសាការសរសេរតាមអានទេ។

## ៣. កាលវិភាគប្រព្រឹត្តទៅនៃវិញ្ញាសា

### ថ្ងៃចន្ទ ទី៦ ខែកក្កដា ឆ្នាំ២០២៦

ពេលព្រឹក៖

- ម៉ោង ០៧ : ៣០ ដល់ម៉ោង ០៩ : ០០ : តែងសេចក្ដី (៩០នាទី)
- ម៉ោង ០៩ : ៣០ ដល់ម៉ោង ១០ : ០០ : គីមីវិទ្យា (៣០នាទី)
- ម៉ោង ១០ : ៣០ ដល់ម៉ោង ១១ : ០០ : ផែនដី និងបរិស្ថានវិទ្យា (៣០នាទី)

ពេលរសៀល៖

- ម៉ោង ១៤ : ០០ ដល់ម៉ោង ១៤ : ៤៥ : រូបវិទ្យា (៤៥នាទី)
- ម៉ោង ១៥ : ១៥ ដល់ម៉ោង ១៥ : ៥៥ : ភូមិវិទ្យា (៤០នាទី)
- ម៉ោង ១៦ : ២៥ ដល់ម៉ោង ១៧ : ១០ : សីលធម៌-ពលរដ្ឋវិជ្ជា (៤៥នាទី)

### ថ្ងៃអង្គារ ទី៧ ខែកក្កដា ឆ្នាំ២០២៦

ពេលព្រឹក៖

- ម៉ោង ០៧ : ៣០ ដល់ម៉ោង ០៩ : ៣០ : គណិតវិទ្យា (១២០នាទី)
- ម៉ោង ១០ : ០០ ដល់ម៉ោង ១១ : ០០ : ការសរសេរតាមអាន (៦០នាទី)

ពេលរសៀល៖

- ម៉ោង ១៤ : ០០ ដល់ម៉ោង ១៤ : ៤៥ : ជីវវិទ្យា (៤៥នាទី)
- ម៉ោង ១៥ : ១៥ ដល់ម៉ោង ១៥ : ៥៥ : ប្រវត្តិវិទ្យា (៤០នាទី)
- ម៉ោង ១៦ : ២៥ ដល់ម៉ោង ១៧ : ១០ : ភាសាបរទេស (៤៥នាទី)

## ៤. វិញ្ញាសាប្រឡង

- គ្រូបង្រៀនថ្នាក់ទី៩ (មុខវិជ្ជាប្រឡងនីមួយៗ) ត្រូវធ្វើសំណើវិញ្ញាសាមួយ ដើម្បីដាក់ជូនគណៈមេប្រយោគមណ្ឌលចាប់ឆ្នោតយកធ្វើជាវិញ្ញាសាប្រឡង១ម៉ោង មុនពេលចាប់ផ្ដើមដំណើរការវិញ្ញាសានីមួយៗ
- នាយក នាយិកាគ្រឹះស្ថានមធ្យមសិក្សាត្រូវប្រជុំណែនាំគ្រូបង្រៀនថ្នាក់ទី៩ គ្រប់មុខវិជ្ជាប្រឡងទាំងអស់ឱ្យធ្វើសំណើវិញ្ញាសា និងអត្រាកំណែ ម្នាក់មួយវិញ្ញាសាដោយយកចិត្តទុកដាក់លើ៖
  + កម្រិតប្លូមតាក់សូណូមីនៃវិញ្ញាសា៖ វិញ្ញាសានីមួយៗត្រូវមានសំណួរ ឬលំហាត់ដែលមានកម្រិតប្លូមតាក់សូណូមីចម្រុះគ្នាពីទាបទៅខ្ពស់យ៉ាងហោចណាស់ដល់កម្រិតទី៤ ក្នុងចំណោមកម្រិតទាំង៦ នៃប្លូមតាក់សូណូមី គឺ៖ ១-កម្រិតចងចាំ ២-កម្រិតយល់ ៣-កម្រិតអនុវត្ត ៤-កម្រិតវិភាគ ៥-កម្រិតវាយតម្លៃ ៦-កម្រិតបង្កើតថ្មី
  + វិញ្ញាសាត្រូវតែជំរុញឱ្យសិស្សចេះគិត ពិចារណា ចេះដោះស្រាយបញ្ហា ចេះវិភាគរកហេតុ និងផល។ ឧទាហរណ៍៖ ហេតុអ្វី... មានចំណុចអវិជ្ជមានអ្វីខ្លះ ?... ធ្វើដូចម្ដេច... ដើម្បី...
  + កម្រិតលំបាកនៃវិញ្ញាសា៖ វិញ្ញាសានីមួយៗ ត្រូវមានសំណួរ ឬលំហាត់ដែលមានកម្រិតលំបាកចម្រុះគ្នាពីងាយទៅលំបាក។ ឧទាហរណ៍ វិញ្ញាសាមួយមាន ៥សំណួរ ត្រូវមានសំណួរងាយ ២សំណួរ សំណួរមធ្យម ២សំណួរ និងសំណួរលំបាក ១សំណួរ

+ ការគ្រប់ដណ្ដប់កម្មវិធីសិក្សា៖វិញ្ញាសានីមួយៗ ត្រូវមានសំណួរ ឬលំហាត់ដែលគ្រប់ដណ្ដប់កម្មវិធីសិក្សា ចាប់ពីជំពូកមេរៀននៅដើមឆ្នាំសិក្សា កណ្ដាលឆ្នាំសិក្សា និងចុងឆ្នាំសិក្សា។ គ្រូបង្រៀនតាមមុខវិជ្ជាត្រូវ លៃលកចេញវិញ្ញាសាមួយដែលមានខ្លឹមសារនៅច្រើនជំពូកមេរៀន ដែលខ្លួនបានបង្រៀន និងសិស្សបាន រៀននៅក្នុងថ្នាក់ នៅក្នុងម៉ោង តាមកាលវិភាគប្រចាំថ្នាក់ តាមគ្រឹះស្ថានមធ្យមសិក្សានីមួយៗ ជាពិសេស នាយក នាយិកាគ្រឹះស្ថានមធ្យមសិក្សាត្រូវជំរុញគ្រូបង្រៀនតាមមុខវិជ្ជានីមួយៗ ឱ្យបង្រៀនបានចប់តាម កម្មវិធីសិក្សាកំណត់របស់ក្រសួង

+ ថេរវេលា និងពិន្ទុនៃវិញ្ញាសា៖ វិញ្ញាសានីមួយៗ ត្រូវមានពិន្ទុ និងថេរវេលាសរុបគិតជានាទី ដូចចែងខាងលើ។ ដើម្បីប៉ាន់ស្មានថេរវេលា នៃវិញ្ញាសានីមួយៗ គេត្រូវប៉ាន់ស្មានថេរវេលានៃសំណួរ ឬលំហាត់នីមួយៗ រួច ទើបបូកសរុបថេរវេលានៃវិញ្ញាសាទាំងមូល។

– ការផលិតវិញ្ញាសាជាសមត្ថកិច្ចរបស់នាយក នាយិកាគ្រឹះស្ថានមធ្យមសិក្សានីមួយៗ គឺអាចប្រើប្រាស់ក្រដាស កាបោន ឬថតចម្លងតាមស្ថានភាពជាក់ស្ដែង

– វិញ្ញាសាគ្រប់មុខវិជ្ជាត្រូវចែកទៅតាមចំនួនបន្ទប់ប្រឡង ដើម្បីឱ្យអនុរក្សចម្លងដាក់លើក្ដារខៀន ដោយមាន អ្នកត្រួតពិនិត្យឱ្យបានត្រឹមត្រូវ លើកលែងតែអត្ថបទសរសេរតាមអានប៉ុណ្ណោះ

– នីតិវិធីនៃការផ្ទៀងផ្ទាត់វិញ្ញាសាកត់លើក្ដារខៀន៖

+ អនុរក្សទី១ ចម្លងវិញ្ញាសាដាក់លើក្ដារខៀន ចំណែកអនុរក្សទី២ គ្រប់គ្រងបេក្ខជនមិនឱ្យចម្លងវិញ្ញាសា ដាក់លើក្រដាសផ្សេងៗ

+ ពេលចម្លងវិញ្ញាសាដាក់លើក្ដារខៀនចប់ ត្រូវប្រគល់សន្លឹកវិញ្ញាសានោះទៅឱ្យអនុរក្សទី២

+ អនុរក្សទី២ អានវិញ្ញាសាដែលទទួលបានពីអនុរក្សទី១ (អានក្នុងសំឡេងល្មមស្ដាប់ឮក្នុងបន្ទប់) ចំណែក អនុរក្សទី១ និងបេក្ខជនទាំងអស់ត្រូវមើលក្ដារខៀនតាម ដើម្បីផ្ទៀងផ្ទាត់សំណេរនៅលើក្ដារខៀន

+ បន្ទាប់ពីផ្ទៀងផ្ទាត់ចប់សព្វគ្រប់ អនុរក្សប្រគល់សន្លឹកវិញ្ញាសាឱ្យទៅអ្នកត្រួតពិនិត្យតាមអគារ ដើម្បី ប្រគល់ទៅប្រធានមណ្ឌលវិញជាបន្ទាន់។

– គ្រឹះស្ថានមធ្យមសិក្សានីមួយៗ មិនអាចចេញវិញ្ញាសាដូចគ្នាបានទេ

– បេក្ខជនទាំងឡាយ អាចជ្រើសរើសយកភាសាបរទេសតែមួយប៉ុណ្ណោះ ក្នុងចំណោមភាសាបារាំង ឬភាសា អង់គ្លេស។ ការជ្រើសរើសភាសាបរទេស ត្រូវយកតាមភាសាដែលបេក្ខជនបានជ្រើសរើសពេលប្រឡង ឆមាសលើកទី១ និងប្រឡងឆមាសលើកទី២

– ពិន្ទុភាសាបរទេស នឹងគិតយកតែពិន្ទុដែលបេក្ខជនធ្វើបានលើសពី ២៥ ទៅបូកបញ្ចូលជាមួយពិន្ទុមុខវិជ្ជា ផ្សេងៗទៀត

– សិស្សសាលាឯកជនដែលបានរៀនមុខវិជ្ជានានាជាភាសាអង់គ្លេស លើកលែងមុខវិជ្ជាភាសាខ្មែរ មិនតម្រូវឱ្យ ប្រឡងវិញ្ញាសាភាសាបរទេសទេ

– វិញ្ញាសាប្រឡងត្រូវយកតាមកម្មវិធីសិក្សាថ្នាក់ទី៩ នៃមធ្យមសិក្សាបឋមភូមិ។ វិញ្ញាសាទាំងអស់ជាវិញ្ញាសា សរសេរ

– ចំពោះបេក្ខជនពិការភ្នែក អនុរក្សត្រូវអានវិញ្ញាសាឱ្យបេក្ខជនស្ដាប់ ឬកត់ត្រា ដើម្បីធ្វើចម្លើយហើយត្រូវ ទូទាត់រយៈពេលហៅវិញ្ញាសាតែមិនឱ្យប៉ះពាល់ដល់ការប្រព្រឹត្តទៅនៃវិញ្ញាសាបន្ទាប់។ គណៈមេប្រយោគមណ្ឌល សំណេរត្រូវសម្រេចដកសំណួរណាដែលពាក់ព័ន្ធនឹងគំនូរ

– សិស្សសាលាឯកជនដែលបានរៀនមុខវិជ្ជានានាជាភាសាអង់គ្លេស អនុរក្សត្រូវបកប្រែវិញ្ញាសាគ្រប់មុខវិជ្ជា

ជាភាសាអង់គ្លេស លើកលែងតែវិញ្ញាសាតែងសេចក្តី និងសរសេរតាមអាន ហើយត្រូវទូទាត់រយៈពេលបកប្រែវិញ្ញាសានោះតែមិនឱ្យប៉ះពាល់ដល់ការប្រព្រឹត្តទៅនៃវិញ្ញាសាបន្ទាប់

- ហាមដាច់ខាតយកទូរសព្ទ និងឧបករណ៍អេឡិចត្រូនិកចូលបន្ទប់ប្រឡង។ បេក្ខជនដែលប្រើទូរសព្ទក្នុងបន្ទប់ប្រឡងនឹងបានពិន្ទុសូន្យ ព្រមទាំងបណ្តេញចេញឈប់ឱ្យប្រឡងបន្តទៀត។

## ៥. សន្លឹកកិច្ចការបេក្ខជន

- បេក្ខជនត្រូវប្រើក្រដាសសៀវភៅផ្ទាល់ខ្លួនធ្វើជាក្រដាសប្រឡងនិងត្រូវបំពេញក្បាលសន្លឹកកិច្ចការ (គំរូជូនភ្ជាប់)
- ក្នុងពេលកែសន្លឹកកិច្ចការបេក្ខជនមិនចាំបាច់កាត់ក្បាលទេ
- សន្លឹកកិច្ចការរបស់បេក្ខជនពិការភ្នែក ត្រូវកែដោយលោកគ្រូ អ្នកគ្រូមកពីវិទ្យាល័យអប់រំពិសេស។

## ៦. ពិន្ទុកំណត់ឱ្យជាប់ និងនិទ្ទេស

- ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ រយៈពេលប្រឡង ២ថ្ងៃ ស្មើនឹង ៥៩០នាទី មានបេបពិន្ទុអតិបរមា ៤៤៥ពិន្ទុ និងបេបពិន្ទុប្រចាំឆ្នាំ ១០០ពិន្ទុ។ ពិន្ទុសរុប : ៤៤៥ + ១០០ = ៥៤៥ ប៉ុន្តែដោយភាសាបរទេសជាវិញ្ញាសាតាមស្ម័គ្រ ដូចនេះពិន្ទុប្រឡងជាប់គឺ ៥៤៥ ដក ២៥ រួចចែកនឹង ២ ស្មើនឹង ២៦០ពិន្ទុ (សម្រាប់បេក្ខជនចំណេះទូទៅ និងបំពេញវិជ្ជា) ចំពោះបេក្ខជនស្វៃរិន ពិន្ទុប្រឡងជាប់គឺ ៤៤៥ ដក ២៥ រួចចែកនឹង ២ ស្មើនឹង ២១០ពិន្ទុ
- ចំពោះបេក្ខជនអវត្តមាន ចាប់ពីមួយវិញ្ញាសាឡើងទៅត្រូវកំណត់ឱ្យធ្លាក់ជាស្វ័យប្រវត្តិ និងត្រូវចុះអក្សរ " A " នៅក្នុងតារាងស្រង់ពិន្ទុ ដោយមិនចាំបាច់បូកពិន្ទុដាក់ក្នុងខ្ទង់ពិន្ទុសរុបឡើយ
- ចំពោះបេក្ខជនដែលមិនបានប្រគល់សន្លឹកកិច្ចការវិញ្ញាសាណាមួយដល់គណៈមេប្រយោគ ត្រូវចាត់ទុកបេក្ខជននោះអវត្តមានចំពោះវិញ្ញាសានោះហើយត្រូវអនុវត្តដូចករណីបេក្ខជនអវត្តមានដូចបានរៀបរាប់ខាងលើ។ ករណីនេះអនុរក្សត្រូវធ្វើកំណត់ហេតុពិសេសដោយមានការចូលរួមទទួលស្គាល់ពីអប្បមាទ និងប្រធានមណ្ឌល
- ចំពោះបេក្ខជនដែលមកប្រឡងគ្រប់វិញ្ញាសាទាំងអស់ លើកលែងតែវិញ្ញាសាភាសាបរទេសដែលជាវិញ្ញាសាតាមស្ម័គ្រ ត្រូវបូកពិន្ទុ និងកំណត់ឱ្យជាប់តាមធម្មតា ទោះបីមានវិញ្ញាសាណាមួយ ឬច្រើនបានពិន្ទុសូន្យក៏ដោយ
- និទ្ទេសត្រូវបានកំណត់ ដូចតទៅ៖
  + ចំពោះបេក្ខជននៃគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ និងឯកជន៖
    * ចាប់ពីពិន្ទុ ២៦០ ទៅពិន្ទុ ៣៣៧ និទ្ទេស : មធ្យម
    * ចាប់ពីពិន្ទុ ៣៣៨ ទៅពិន្ទុ ៤១៥ និទ្ទេស : ល្អបង្គួរ
    * ចាប់ពីពិន្ទុ ៤១៦ ឡើងទៅ និទ្ទេស : ល្អ។
  + ចំពោះបេក្ខជនស្វៃរិន៖
    * ចាប់ពីពិន្ទុ ២១០ ទៅពិន្ទុ ២៧២ និទ្ទេស : មធ្យម
    * ចាប់ពីពិន្ទុ ២៧៣ ទៅពិន្ទុ ៣៣៥ និទ្ទេស : ល្អបង្គួរ
    * ចាប់ពីពិន្ទុ ៣៣៦ ឡើងទៅ និទ្ទេស : ល្អ។

**សម្គាល់៖**

- សម្រាប់បេក្ខជន គថ្លង់ ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ មានរយៈពេល ២ថ្ងៃ ស្មើនឹង ៥៣០នាទី មានបេបពិន្ទុអតិបរមា ៤០៥ពិន្ទុ និងបេបពិន្ទុប្រចាំឆ្នាំ ១០០ពិន្ទុ។ ពិន្ទុសរុប : ៤០៥ + ១០០ = ៥០៥ ប៉ុន្តែដោយភាសាបរទេសជាវិញ្ញាសាតាមស្ម័គ្រ ដូចនេះពិន្ទុប្រឡងជាប់គឺ ៥០៥ ដក ២៥ រួចចែកនឹង២ ស្មើនឹង ២៤០ពិន្ទុ (សម្រាប់បេក្ខជនចំណេះទូទៅ និងបំពេញវិជ្ជា) ចំពោះបេក្ខជនស្វៃរិន ពិន្ទុប្រឡងជាប់

គឺ ៤០៥ ដក ២៥ រួចចែកនឹង២ ស្មើនឹង ១៩០ពិន្ទុ

– និទ្ទេសសម្រាប់បេក្ខជន គប្លង់ ត្រូវបានកំណត់ ដូចតទៅ៖

  + ចំពោះបេក្ខជននៃគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ និងឯកជន៖

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| * | ចាប់ពីពិន្ទុ | ២៤០ | ទៅពិន្ទុ | ៣១៧ | និទ្ទេស | : | មធ្យម |
| * | ចាប់ពីពិន្ទុ | ៣១៨ | ទៅពិន្ទុ | ៣៩៥ | និទ្ទេស | : | ល្អបង្គួរ |
| * | ចាប់ពីពិន្ទុ | ៣៩៦ | ឡើងទៅ | | និទ្ទេស | : | ល្អ។ |

  + ចំពោះបេក្ខជនសេរី៖

| | | | | | | | |
|---|---|---|---|---|---|---|---|
| * | ចាប់ពីពិន្ទុ | ១៩០ | ទៅពិន្ទុ | ២៥២ | និទ្ទេស | : | មធ្យម |
| * | ចាប់ពីពិន្ទុ | ២៥៣ | ទៅពិន្ទុ | ៣១៥ | និទ្ទេស | : | ល្អបង្គួរ |
| * | ចាប់ពីពិន្ទុ | ៣១៦ | ឡើងទៅ | | និទ្ទេស | : | ល្អ។ |

## ៧. សំណុំលិខិតចុះឈ្មោះប្រឡង

– សំណុំលិខិតដាក់ពាក្យសុំប្រឡងរបស់បេក្ខជន ត្រូវបំពេញដោយដៃបេក្ខជនផ្ទាល់ (គំរូជូនភ្ជាប់) និងមានភ្ជាប់បង្កាន់ដៃបង់សិទ្ធិប្រឡងតម្លៃ ១ ០០០រៀល

– ពាក្យសុំប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ត្រូវភ្ជាប់៖

  + សលាកបត្រឯកត្តជនទំហំ ១៥ស.ម គុណនឹង ២១ស.ម មានបិទរូបថតថ្មី ឬរូបថតឌីជីថលតាមទំហំដែលបានកំណត់ ថតចំពីមុខ ទំហំ ៤ស.ម គុណនឹង ៦ស.ម ចំនួន ២សន្លឹក បង្កាន់ដៃបង់សិទ្ធិប្រឡង ចំនួន ១សន្លឹក

  + រូបថតថ្មី ថតចំពីមុខទំហំ ៤ស.ម គុណនឹង ៦ស.ម "រូបថតដែលបានបិទលើសលាកបត្រឯកត្តជន" ចំនួន ២សន្លឹក ឬរូបថតឌីជីថល តាមទំហំដែលបានកំណត់

  + សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬ សំបុត្របញ្ជាក់កំណើតចំនួន ១សន្លឹក (ថតចម្លង)

  + សៀវភៅសិក្ខាគារិក (ចំពោះសិស្សគ្រឹះស្ថានមធ្យមសិក្សាឯកជន)

– ការភ្ជាប់សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬ សំបុត្របញ្ជាក់កំណើត បេក្ខជនត្រូវថតចម្លង**ដោយពុំចាំបាច់ធ្វើនិត្យានុកូលកម្ម**។ ចំពោះមន្ត្រីទទួលសំណុំលិខិតដាក់ពាក្យសុំប្រឡង គ្រាន់តែយកឯកសារថតចម្លង និងឯកសារច្បាប់ដើមមកផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវដើម្បីចៀសវាងការកោសលុប ឬលុបកែខុសពីលំនាំច្បាប់ដើមនិងត្រូវបញ្ជាក់ដោយអ្នកទទួលខុសត្រូវពិនិត្យផ្ទៀងផ្ទាត់ឯកសារ (ពិតជាត្រឹមត្រូវតាមច្បាប់ដើម) ដោយចុះហត្ថលេខា និងឈ្មោះអ្នកពិនិត្យជាសម្គាល់

– ការចំណាយរបស់សិស្សម្នាក់លើថ្លៃសិទ្ធិប្រឡង និងសំណុំឯកសារសម្រាប់ដាក់ពាក្យសុំប្រឡង យ៉ាងច្រើន ២ ២០០រៀល

– ចំពោះសន្លឹកបង្កាន់ដៃបង់សិទ្ធិប្រឡង នាយក នាយិកាគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ ត្រូវទៅស្នើសុំពីមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងត្រូវប្រមូលថវិកាដែលទទួលបានពីការបង់ថ្លៃសិទ្ធិប្រឡងនេះជូនវិញដើម្បីមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត យកទៅបង់បន្តនៅគេនាគារ

– នាយក នាយិកាគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ ត្រូវប្រើប្រាស់ថវិកាដែលនៅសល់ ក្រោយពេលបង់ថ្លៃសិទ្ធិប្រឡង សម្រាប់ការចំណាយលើការថតចម្លងសំណុំលិខិតដាក់ពាក្យសុំប្រឡង ថ្លៃថតចម្លងវិញ្ញាសាសម្រាប់ចែកតាមបន្ទប់ប្រឡងនីមួយៗ និងចំណាយផ្សេងៗទៀតដូចជាការទិញក្រដាសកាបោន ហ្វីត ឬ ជីសសម្រាប់កត់វិញ្ញាសាដាក់លើក្តារខៀន។ល។

**៨. បេក្ខភាពប្រឡង**

សិស្សគ្រឹះស្ថានមធ្យមសិក្សាចំណោះទូទៅសាធារណៈ និងឯកជន ដែលៈ

- បានរៀននៅមធ្យមសិក្សាបឋមភូមិគ្រប់កម្រិតថ្នាក់
- បានរៀនចប់កម្មវិធីសិក្សាថ្នាក់ទី៩
- បានគោរពត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុង សម្រាប់គ្រឹះស្ថានមធ្យមសិក្សា
- ត្រូវបានវាយតម្លៃផ្នែកសីលធម៌ប្រចាំឆ្នាំ ចាប់ពីកម្រិតមធ្យមឡើងទៅ។

អាចដាក់ពាក្យសុំប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ នៅតាមគ្រឹះស្ថានមធ្យមសិក្សារៀងៗខ្លួន ដោយឡែក សិស្សពូកែ ដែលបានរៀនចប់កម្មវិធីសិក្សាមធ្យមសិក្សាបឋមភូមិ ក្រសួងអនុញ្ញាតឱ្យដាក់ពាក្យប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ដោយមិនគិតអាយុឡើយ (សិស្សពូកែសំដៅលើសិស្សពូកែក្នុងសាលា និងមានការទទួលស្គាល់ ឬលិខិតបញ្ជាក់ពីនាយក នាយិកានៃគ្រឹះស្ថានសិក្សារបស់ខ្លួន)។

**ចំពោះសិស្សគ្រឹះស្ថានមធ្យមសិក្សាចំណោះទូទៅសាធារណៈ និងឯកជនពុំអាចទទួលស្គាល់ជាបេក្ខភាពបាន គឺៈ**

- **ករណីទី១ៈ** សិស្សមានមធ្យមភាគពិន្ទុប្រចាំឆ្នាំក្រោម ២៥.០០
- **ករណីទី២ៈ** សិស្សគ្មានមធ្យមភាគពិន្ទុប្រឡងឆមាសៈ
  + ឈប់ឥតច្បាប់ក្នុងពេលប្រឡងឆមាសមុខវិជ្ជាណាមួយ
  + ឈប់មានច្បាប់ក្នុងពេលប្រឡងឆមាសចាប់ពី ៣មុខវិជ្ជាឡើងទៅ។
- **ករណីទី៣ៈ** សិស្សអវត្តមានលើសពីចំនួនកំណត់ៈ
  + អវត្តមានឥតច្បាប់លើសពី ៣០ដងឡើងទៅ
  + អវត្តមានឥតច្បាប់ និងមានច្បាប់លើសពី ៤០ដងឡើងទៅ
  + អវត្តមានមានច្បាប់លើសពី ៥៥ដងឡើងទៅ។

ចំពោះសិស្សមកពីសាលារៀនបំពេញវិជ្ជា សាលារៀនឯកជន សាលារៀនអង្គការត្រូវដាក់ពាក្យសុំចុះឈ្មោះប្រឡងនៅគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ ដែលនៅជិតជាងគេ ឬនៅជិតជាងគេបន្ទាប់ ក្នុងនោះៈ

- អតីតបេក្ខជនដែលបានប្រឡងធ្លាក់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ អាចដាក់ពាក្យសុំចុះឈ្មោះប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ជាបេក្ខជនស្វែរិននៅតាមគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ ដែលសាមីខ្លួនបានសុំប្រឡងពីមុន ដោយភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ការប្រឡងធ្លាក់ពីមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដែលសាមីខ្លួនបានប្រឡងធ្លាក់ពីមុន
- ចំនួនអវត្តមានត្រូវគិតចាប់ពីបវេសនកាលហូតដល់**ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៦**។

**៩. ការអនុវត្តវិធានការសុខាភិបាល**

ដើម្បីបង្ការជំងឺ ថែទាំសុខភាពបុគ្គលិកអប់រំ និងសិស្សានុសិស្សអំឡុងពេលត្រៀមប្រឡង និងប្រឡងត្រូវលើកកម្ពស់សុខភាពសិក្សា តាមការណែនាំរបស់ការិយាល័យជំនាញ នៃមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងនាយកដ្ឋានសុខភាពសិក្សានៃក្រសួង និងអនុវត្តវិធានការសុខាភិបាល ដូចមានកំណត់ក្នុងសេចក្ដីណែនាំប្រតិបត្តិលេខ ៣៤ អយក.សណន ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២២។ ពិសេសក្នុងករណីចាំបាច់ បន្ទាន់ណាមួយ ត្រូវយកចិត្តទុកដាក់ក្នុងការអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល។

**១០. ការទទួលសំណុំលិខិតដាក់ពាក្យសុំប្រឡង**

នាយក នាយិកាគ្រឹះស្ថានមធ្យមសិក្សាៈ

- ត្រូវរាប់ចំនួនសិស្សដាក់ពាក្យសុំប្រឡង ទៅតាមបញ្ជីសុំបេក្ខភាពប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ

ដើម្បីទុកផ្ញើជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចេញសេចក្ដីសម្រេចកំណត់មណ្ឌលប្រឡង
- ត្រូវពិនិត្យសំណុំលិខិតដាក់ពាក្យសុំប្រឡងរបស់សិស្ស ដោយផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវនូវឈ្មោះ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុក ឈ្មោះម្ដាយរបស់សិស្ស ដែលសរសេរក្នុងពាក្យសុំប្រឡង និងសលាកបត្រឯកត្តជន ដោយយកសេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត ឬ សំបុត្របញ្ជាក់កំណើតធ្វើជាគោល។ ពាក្យសុំចុះឈ្មោះប្រឡង និងសលាកបត្រឯកត្តជន ត្រូវណែនាំសិស្សសរសេរឱ្យបានច្បាស់
- ត្រូវណែនាំឱ្យសិស្សសរសេរសំណុំលិខិតដាក់ពាក្យសុំប្រឡងដោយខ្លួនឯង ចៀសវាងប្រមូលយកទៅឱ្យគ្រូទទួលបន្ទុកថ្នាក់ ឬ មិត្តភក្ដិ ឬ អ្នកដទៃសរសេរជំនួស។

## ១១. ការរៀបចំមណ្ឌលប្រឡង និងបន្ទប់

- គ្រប់គ្រឹះស្ថានមធ្យមសិក្សាសាធារណៈទាំងអស់ ដែលមានសិស្សថ្នាក់ទី៩ ត្រូវបានកំណត់ជាមណ្ឌលប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ (គំរូជូនភ្ជាប់)
- ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវចេញសេចក្ដីសម្រេចស្ដីពីការកំណត់មណ្ឌលប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងយកមកប្រគល់ជូននាយកដ្ឋានកិច្ចការប្រឡង (ការិយាល័យប្រឡងតាមរយៈ Telegram៖ ០១២ ៧៣៦ ៧៦៧) ចំនួន ២ច្បាប់
- នាយក នាយិកាគ្រឹះស្ថានមធ្យមសិក្សា ត្រូវប្ដូរក្ដារខៀន ដែលចាស់រេចរឹល មានស្នាមរលាត់ ប្រឡាក់លុបមិនជ្រះ និងដោះផ្ទាំងរូបមន្តដែលបិទនៅតាមជញ្ជាំងបន្ទប់ប្រឡង ឱ្យបានមុនដំណើរការប្រឡង
- នាយក នាយិកាគ្រឹះស្ថានមធ្យមសិក្សា ត្រូវសម្អាតទីធ្លា ធ្វើអនាម័យអគារ បន្ទប់ប្រឡងឱ្យបានស្អាត និងរៀបចំតុសម្រាប់បេក្ខជនចំនួន ២៥នាក់ គ្រប់បន្ទប់ប្រឡងនីមួយៗ មុនដំណើរការប្រឡង
- ត្រូវរៀបបេក្ខជនក្នុងមួយបន្ទប់ ២៥នាក់ លើកលែងតែបន្ទប់ចុងក្រោយដែលមានចំនួនសិស្សតិចជាង ២៥នាក់
- បញ្ជីឈ្មោះបេក្ខជន ត្រូវរៀបតាមលំដាប់អក្ខរក្រម មានលេខបន្ទប់ និងលេខតុ (គំរូជូនភ្ជាប់)
- មណ្ឌលប្រឡងនីមួយៗ ត្រូវមានឧបករណ៍បំពងសំឡេង ដែលអាចប្រើប្រាស់បាននៅពេលដំណើរកាប្រឡង
- នាយក នាយិកាគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ ដែលជាមណ្ឌលប្រឡង ត្រូវដើរតួនាទីជាប្រធានមណ្ឌលប្រឡង និងមានភារកិច្ចចុះហត្ថលេខាលើតារាងប្រព្រឹត្តទៅនៃវិញ្ញាសា បញ្ជីឈ្មោះបេក្ខជន តារាង ស្រង់ពិន្ទុ និងបញ្ជីគូសជាប់ ធ្លាក់។

## ១២. ការរៀបចំ និងការឧបត្ថម្ភគណៈមេប្រយោគ

- នាយក នាយិកា និងនាយករង នាយិការងដែលទទួលបន្ទុកផ្នែកមធ្យមសិក្សាបឋមភូមិ នៃគ្រឹះស្ថានមធ្យមសិក្សាសាធារណៈដែលជាមណ្ឌលប្រឡង គឺជាប្រធានមណ្ឌល និងអនុប្រធានមណ្ឌល ចាប់តាំងពីដំណើរការសំណេរ កំណែ ស្រង់បូកពិន្ទុ និងគូសជាប់ ធ្លាក់
- ប្រធាន អនុប្រធានមណ្ឌលត្រូវសហការគ្នា និងម្ចាស់ការរៀបចំ និងចុះហត្ថលេខាលើលិខិតឧទ្ទេសនាមគណៈមេប្រយោគនានា តាមដំណាក់កាលនៃការប្រឡង រួមមានដំណើរការសំណេរ ដំណើរការកំណែ និងដំណើរការស្រង់បូកពិន្ទុ និងគូសជាប់ ធ្លាក់ ដោយប្រើប្រាស់បុគ្គលិកអប់រំទទួលបន្ទុកផ្នែកមធ្យមសិក្សាបឋមភូមិ នៅក្នុងគ្រឹះស្ថានមធ្យមសិក្សាសាធារណៈរបស់ខ្លួន ធ្វើជាមេប្រយោគ
- គណៈមេប្រយោគដែលបានចាត់តាំង ក្នុងដំណើរការសំណេរនឹងត្រូវទទួលបានការឧបត្ថម្ភដោយថវិកាជាតិតាមគោលការណ៍កំណត់ ដោយគិតរយៈពេលបំពេញការងារ ៣ថ្ងៃ រួមមាន៖
    + ប្រធាន អនុប្រធានមណ្ឌលប្រឡង
    + គណៈកម្មការត្រួតពិនិត្យតាមអគារ

+ គណៈកម្មការកណ្ដាល
+ គណៈកម្មការអនុរក្ស។

- គណៈមេប្រយោគ ដែលបានចាត់តាំងក្នុងដំណើរការកំណែនឹងត្រូវទទួលបានការឧបត្ថម្ភដោយថវិការដ្ឋតាមគោលការណ៍កំណត់ដោយគិតរយៈពេលបំពេញការងារ ៣ថ្ងៃ រួមមាន៖
  + ប្រធាន អនុប្រធានមណ្ឌលកំណែ
  + គណៈកម្មការបែងចែកសន្លឹកកិច្ចការ
  + គណៈកម្មការកំណែនឹងត្រូវបានទទួលការឧបត្ថម្ភដោយថវិការដ្ឋតាមគោលការណ៍កំណត់ដោយគិតរយៈពេលបំពេញការងារ ៤ថ្ងៃ ដោយគិតទាំងការឧបត្ថម្ភលើការស្នើប្រធានវិញ្ញាសាផង លើកលែងតែគណៈកម្មការកំណែមុខវិជ្ជាភាសាខ្មែរ ដែលត្រូវញែកចេញជាពីរគឺ៖ តែងសេចក្តី និងការសរសេរតាមអាន ត្រូវបានគិតរយៈពេលបំពេញការងារ ៦ថ្ងៃ។
- គណៈមេប្រយោគដែលបានចាត់តាំងក្នុងដំណើរការស្រង់បូកពិន្ទុ និងគូសជាប់ ធ្លាក់ នឹងត្រូវបានទទួលការឧបត្ថម្ភដោយថវិការដ្ឋ តាមគោលការណ៍កំណត់ដោយគិតរយៈពេលបំពេញការងារ ៣ថ្ងៃ រួមមាន៖
  + ប្រធាន អនុប្រធានមណ្ឌលស្រង់បូកពិន្ទុ និងគូសជាប់ ធ្លាក់
  + គណៈកម្មការស្រង់បូកពិន្ទុ និងគូសជាប់ ធ្លាក់។
- ដោយឡែកប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវរៀបចំ និងចុះហត្ថលេខាលើលិខិតឧទ្ទេសនាមគណៈកម្មការគណនេយ្យ ដែលត្រូវជ្រើសរើសក្នុងចំណោមបុគ្គលិកអប់រំនៃមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដោយគិតនិយាម ១នាក់ សម្រាប់បេក្ខជន ២ ០០០នាក់ ហើយចំពោះខេត្តដែលមានបេក្ខជនតិចជាង ២ ០០០នាក់ ត្រូវមានគណៈកម្មការនេះ ១នាក់ និងត្រូវបានទទួលប្រាក់ឧបត្ថម្ភដោយថវិការដ្ឋតាមរបបម៉ៅការ និងតាមគោលការណ៍កំណត់។ គណៈកម្មការគណនេយ្យមានភារកិច្ចរៀបចំបើកថវិកាឧបត្ថម្ភគណៈមេប្រយោគ និងប្រមូលឯកសារទូទាត់ការចំណាយ
- ចំពោះភារកិច្ចផ្សេងៗដទៃទៀត គឺជាការទទួលខុសត្រូវរបស់នាយក នាយិកា និងនាយករង នាយិការងនៃគ្រឹះស្ថានមធ្យមសិក្សាសាធារណៈនីមួយៗ ដែលនឹងទទួលបានប្រាក់ឧបត្ថម្ភចាប់តាំងពីដំណើរការសំណេរ កំណែ ស្រង់បូកពិន្ទុ និងគូសជាប់ ធ្លាក់ សរុប ៩ថ្ងៃ
- បុគ្គលិកអប់រំ ដែលព្យួរការងារ លំហែមាតុភាព គ្រូបង្រៀនមកពីសាលារៀនឯកជន សាលារៀនក្រៅពីគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ ដែលជាមណ្ឌលប្រឡង មិនអនុញ្ញាតឱ្យចូលរួមជាគណៈមេប្រយោគទេ លើកលែងតែគ្រូបង្រៀនដែលត្រូវមកបកប្រែវិញ្ញាសា កែកិច្ចការបេក្ខជនជាភាសាអង់គ្លេស យ៉ាងច្រើន ១នាក់ក្នុង១មុខវិជ្ជា សម្រាប់មណ្ឌលប្រឡងដែលមានបេក្ខជនប្រឡងគ្រប់មុខវិជ្ជាជាភាសាអង់គ្លេស លើកលែងតែភាសាខ្មែរ
- ប្រធានមណ្ឌល ត្រូវចាត់តាំងប្រធានក្រុមកំណែតាមមុខវិជ្ជាដើម្បីដឹកនាំធ្វើអត្រាកំណែ និងដឹកនាំកែកិច្ចការបេក្ខជន
- គណៈកម្មការកំណែត្រូវជ្រើសរើសក្នុងចំណោមគ្រូបង្រៀនថ្នាក់ទី៩ មុខវិជ្ជាប្រឡង។ គណៈកម្មការផ្សេងទៀតត្រូវជ្រើសរើសក្នុងចំណោមគ្រូបង្រៀនថ្នាក់ទី៩ (មុខវិជ្ជាមិនប្រឡង) គ្រូបង្រៀនថ្នាក់ទី៧ ថ្នាក់ទី៨ (គ្រប់មុខវិជ្ជា) និងបុគ្គលិកការិយាល័យដែលទទួលបន្ទុកផ្នែកមធ្យមសិក្សាបឋមភូមិ
- នាយក នាយិកានៃគ្រឹះស្ថានមធ្យមសិក្សាសាធារណៈនីមួយៗ ត្រូវម្ចាស់ការទទួលខុសត្រូវក្នុងការរៀបចំគណៈកម្មការប្រឡងទាំងអស់ ធ្វើយ៉ាងណាចៀសវាងឱ្យខានតែបាននូវរាល់បាតុភាពអសកម្ម ដែលកើតឡើងជាយថាហេតុ។

## ១៣. កម្មវិធីការងារប្រឡង

- ថ្ងៃទី១ (ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៦)៖
  + ពេលព្រឹក៖ ប្រធាន អនុប្រធានមណ្ឌលត្រូវបិទបញ្ជីឈ្មោះបេក្ខជន តារាងប្រព្រឹត្តទៅនៃវិញ្ញាសាប្រឡង ប្លង់បន្ទប់ និងស្លាកលេខបន្ទប់ នៅតាមបន្ទប់ប្រឡង
  + ពេលរសៀល៖ ប្រធាន អនុប្រធានមណ្ឌលប្រជុំណែនាំមេប្រយោគនៅតាមមណ្ឌលសំណេររៀងៗខ្លួន
- ថ្ងៃទី២-៣ (ថ្ងៃទី៦-៧ ខែកក្កដា ឆ្នាំ២០២៦)៖ ដំណើរការសំណេរ (ចន្ទ-អង្គារ)
- ថ្ងៃទី៤-៦ (ថ្ងៃទី៨-១០ ខែកក្កដា ឆ្នាំ២០២៦)៖ ដំណើរការកំណែ
- ថ្ងៃទី៧-៩ (ថ្ងៃទី១១-១៣ ខែកក្កដា ឆ្នាំ២០២៦)៖ ដំណើរការស្រង់បូកពិន្ទុ និងគូសជាប់ ធ្លាក់ និងប្រកាសលទ្ធផល។

## ១៤. សំណុំឯកសារគំរូជូនភ្ជាប់

- ពាក្យសុំចុះឈ្មោះជាបេក្ខជនប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ (គំរូទី១)
- ពាក្យសុំចុះឈ្មោះជាបេក្ខជនស្វៃរិនប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ (គំរូទី២)
- សលាកបត្រឯកត្តជន (គំរូទី៣)
- បញ្ជីរាយនាមបេក្ខជនប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ (គំរូទី៤)
- តារាងស្រង់ពិន្ទុប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ (គំរូទី៥)
- បញ្ជីរាយនាមបេក្ខជនប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ (បញ្ជីគូសជាប់ ធ្លាក់) (គំរូទី៦)
- លិខិតឧទ្ទេសនាម សម្រាប់ដំណើរការសំណេរ (គំរូទី៧)
- លិខិតឧទ្ទេសនាម សម្រាប់ដំណើរការកំណែ (គំរូទី៨)
- លិខិតឧទ្ទេសនាម សម្រាប់ដំណើរការស្រង់បូកពិន្ទុ និងគូសជាប់ ធ្លាក់ (គំរូទី៩)
- ក្បាលសន្លឹកកិច្ចការបេក្ខជន (គំរូទី១០)
- សេចក្តីសម្រេច ស្តីពីការកំណត់មណ្ឌលប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ (គំរូទី១១)
- ស្ថិតិបេក្ខជនប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ (គំរូទី១២)
- តារាងប្រព្រឹត្តទៅនៃវិញ្ញាសា (គំរូទី១៣)
- តារាងស្រង់ពិន្ទុឆមាសលើកទី១ (គំរូទី១៤)

## ១៥. ការផ្តល់សំណុំឯកសារមកនាយកដ្ឋានកិច្ចការប្រឡង

### ក- បញ្ចប់ការប្រឡងឆមាស មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តត្រូវប្រគល់សំណុំឯកសារមកនាយកដ្ឋានកិច្ចការប្រឡង រួមមាន៖

- តារាងស្រង់ពិន្ទុប្រចាំឆមាសលើកទី១ ពីគ្រប់គ្រឹះស្ថានមធ្យមសិក្សាដែលមានបេក្ខជនប្រឡង ចំនួន ១ច្បាប់
- ស្ថិតិបេក្ខជនតាមប្រភេទ ពីគ្រប់គ្រឹះស្ថានមធ្យមសិក្សាដែលមានបេក្ខជនប្រឡង (គំរូ.A) ចំនួន ១ច្បាប់
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តបូកសរុប (គំរូ.B) និង(គំរូទី១៤) ប្រគល់មកក្រសួង (ការិយាល័យប្រឡង តាមរយៈ Telegram៖ ០១២ ៧៣ ៦៧ ៦៧) ឱ្យបានមុន**ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៦** ជាកំហិត។
- តារាងស្រង់ពិន្ទុប្រចាំឆមាសលើកទី២ និងប្រចាំឆ្នាំពីគ្រប់គ្រឹះស្ថានមធ្យមសិក្សាដែលមានបេក្ខជនប្រឡង ចំនួន ១ច្បាប់
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តបូកសរុបប្រគល់មកក្រសួង (ការិយាល័យប្រឡង តាមរយៈ Telegram៖ ០១២ ៧៣ ៦៧ ៦៧) (គំរូ.B) ឱ្យបានមុន**ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៦** ជាកំហិត។

**ខ- បញ្ចប់ការប្រឡង** ( ក្រោយពេលប្រកាសលទ្ធផលប្រឡង ថ្ងៃចន្ទ ទី១៣ ខែកក្កដា ឆ្នាំ២០២៦ )

គ្រឹះស្ថានមធ្យមសិក្សានីមួយៗ ត្រូវប្រគល់ជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត៖

- សលាកបត្រឯកត្តជន ចំនួន ១ច្បាប់
- រូបថតថ្មី ថតចំពីមុខ ទំហំ ៤ គុណនឹង៦ ចំនួន ២សន្លឹក ឬរូបថតឌីជីថល តាមទំហំដែលបានកំណត់
- បញ្ជីគូសជាប់ ធ្លាក់ ចំនួន ២ច្បាប់
- តារាងស្រង់ពិន្ទុ ចំនួន ២ច្បាប់
- ទិន្នន័យបេក្ខជន ប្រឡងជាប់មានចុះនិទ្ទេស និងរូបថត (Soft copy ១កញ្ចប់ ក្នុងមួយគ្រឹះស្ថានមធ្យមសិក្សា)

** ករណីចាំបាច់បន្ទាន់ ក្រសួង នាយកដ្ឋានកិច្ចការប្រឡង ការិយាល័យជំនាញមានសិទ្ធិកែប្រែ ស្នើសុំទិន្នន័យផ្សេងៗ ទាក់ទងនឹងការងារប្រឡង...។

**គ- មុនថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៦**

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវយកមកប្រគល់ជូនក្រសួងអប់រំ យុវជន និងកីឡា ការិយាល័យប្រឡង នៃនាយកដ្ឋានកិច្ចការប្រឡង តាមរយៈ Telegram៖ ០១២ ៧៣ ៦៧ ៦៧ ដូចជា៖

- បញ្ជីគូសជាប់ ធ្លាក់ ចំនួន ១ច្បាប់
- តារាងស្រង់ពិន្ទុ ចំនួន ១ច្បាប់
- ស្ថិតិបេក្ខជនប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ចំនួន ២ច្បាប់
- របាយការណ៍សរុបរួមស្តីពីដំណើរការប្រឡងចាប់ពីដំណើរការចេញវិញ្ញាសា រហូតដល់ប្រកាសលទ្ធផល ចំនួន ២ច្បាប់
- ទិន្នន័យបេក្ខជន ប្រឡងជាប់មានចុះនិទ្ទេស និងរូបថត (Soft copy ១កញ្ចប់ ក្នុងមួយរាជធានី ខេត្ត)។

ក្រសួងសង្ឃឹមថា លោកនាយក លោកស្រីនាយិកាតាមគ្រឹះស្ថានមធ្យមសិក្សា លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តផ្សព្វផ្សាយ និងអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាព ដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ ពុធ ១១រោច ខែ បុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋបាលរាជធានី ខេត្ត
- អង្គភាពក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡា
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- គ្រឹះស្ថានមធ្យមសិក្សាសាធារណៈ និងឯកជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានកិច្ចការប្រឡង